01369539

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 12 / 2016
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E443/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**Declassified to Public**
**05 April 2019**

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សេចក្តីសម្រេចលើសំណើសុំឲ្យទទួលយកសៀវភៅកំណត់ត្រាធ្វើជាឯកសារភស្តុតាង និងកោះហៅសារជាថ្មីនូវសាក្សីពីររូប ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ (សម្ងាត់)

១. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា ខ្លួនបានទទួលសៀវភៅកំណត់ត្រា ស-២១ ពីសាស្ត្រាចារ្យ Walter Heynowski និងបានផ្តល់ឯកសារអេឡិចត្រូនិកនៃសៀវភៅនេះដល់ភាគី ព្រមទាំងអនុញ្ញាតឱ្យភាគីចូលពិនិត្យមើលឯកសារច្បាប់ដើមនៃសៀវភៅនេះផងដែរ (*សូមមើល* ឯកសារ E443/2)។ នាពេលនេះ អង្គជំនុំជម្រះបានស្តាប់សំណើផ្ទាល់មាត់ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ សុំឱ្យទទួលយកសៀវភៅកំណត់ត្រានេះ ជាឯកសារភស្តុតាង។ សហព្រះរាជអាជ្ញាអះអាងថា សៀវភៅកំណត់ត្រានេះ គឺមានភាពពាក់ព័ន្ធយ៉ាងជិតស្និទ្ធ ដោយហេតុថា វាបានបង្ហាញអំពីកំណត់ត្រាប្រចាំថ្ងៃនូវចំនួនមនុស្សចេញនិងចូល នៅមន្ទីរសន្តិសុខ ស-២១ ក្នុងរយៈពេល ៨ ខែ នៅក្នុងឆ្នាំ ១៩៧៧ (ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ទំព័រ (ភាសាអង់គ្លេស) ៩-១០ (សេចក្តីព្រាង))។ មេធាវីការពារក្តី នួន ជា

យល់ស្របផងដែរថា ឯកសារនេះមានភាពពាក់ព័ន្ធយ៉ាងជិតស្និទ្ធ និងមិនមានការជំទាស់ចំពោះការទទួលយកឯកសារនេះ ជាឯកសារភ័ស្តុតាងនោះទេ (ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ទំព័រ ៤២-៤៣)។ មេធាវីការពារក្តី ខៀវ សំផន អះអាងថា ប្រសិនបើសៀវភៅកំណត់ត្រានេះត្រូវបានទទួលយកជាឯកសារភ័ស្តុតាង នោះ អង្គជំនុំជម្រះគួរកោះហៅ ឌុច និង សួស ធី ឱ្យមកផ្តល់សក្ខីកម្មសាជាថ្មីផងដែរ ដើម្បីធ្វើការសួរដេញដោលលើយថាភាពនៃឯកសារនេះ ព្រោះវាជាលើកដំបូងដែលភាគីបានឃើញសៀវភៅកំណត់ត្រាច្បាប់ដើមបែបនេះ។ មេធាវីការពារក្តីក៏បានស្នើសុំអង្គជំនុំជម្រះឱ្យកោះហៅសាស្ត្រាចារ្យ Heynowski ដើម្បីមកផ្តល់សក្ខីកម្ម ស្តីពីកិច្ចដំណើរការនៃការរក្សាឯកសារ និងចំណារដែលមាននៅលើឯកសារនោះផងដែរ (ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ទំព័រ (ភាសាអង់គ្លេស) ១៦-១៧ (សេចក្តីព្រាង))។

២. អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកភ័ស្តុតាងទាំងឡាយណាដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់ការស្វែងរកការពិត នៅពេលដែលភ័ស្តុតាងនោះ បំពេញទៅតាមបទដ្ឋាន *ការបញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះ នឹងសម្រេចលើសំណើសុំឱ្យទទួលយកភ័ស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

៣. អង្គជំនុំជម្រះយល់ឃើញថា សៀវភៅកំណត់ត្រាពណ៌ទឹកក្រូច មានភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទីតាំងឧក្រិដ្ឋមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនាពេលបច្ចុប្បន្ននេះ។ អង្គជំនុំជម្រះយល់ឃើញថា ឯកសារនេះមានភាពពាក់ព័ន្ធ និងអាចជឿជាក់បាន (រួមទាំងមានយថាភាព) បំពេញទៅតាមបទដ្ឋាន*ការបញ្ជាក់បឋម*។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចទទួលយកសៀវភៅកំណត់ត្រាពណ៌ទឹកក្រូចនេះជាឯកសារភ័ស្តុតាង និងដាក់លេខយោងជាឯកសារ E3/10770។

៤. សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឱ្យកោះហៅ សួស ធី និង ឌុច សាជាថ្មី ដើម្បីបញ្ជាក់ពីយថាភាព និងធ្វើសក្ខីកម្មលើខ្លឹមសារនៃសៀវភៅកំណត់ត្រានេះ ត្រូវបានអង្គជំនុំជម្រះបដិសេធមិនកោះហៅ។ នៅពេលសាក្សីទាំងពីររូបនេះ បានមកផ្តល់សក្ខីកម្មនៅក្នុង

សំណុំរឿង ០០២/០២ ពួកគេត្រូវបានបង្ហាញនូវសម្រង់ខ្សែភាពយន្តដែលមានចំណងជើងថា "*Die Angkar*" ដោយបានបង្ហាញនូវសៀវភៅកំណត់ត្រាពណ៌ទឹកក្រូចដែលទទួលបានពីសាស្ត្រាចារ្យ Heynowski ដែលជាផលិតកររបស់ខ្សែភាពយន្តនេះ។ សួស ធី បានទទួលស្គាល់ពីអត្ថិភាពនៃសៀវភៅកំណត់ត្រានៅក្នុងខ្សែភាពយន្តនេះ និងបានផ្តល់សក្ខីកម្មថា គាត់មានតួនាទីកាន់កាប់សៀវភៅនេះ(ប្រតិចារឹក ថ្ងៃទី០៦ ខែ មិថុនា ឆ្នាំ ២០១៦ ទំព័រ ៥៦-៦០)។ ឌុច បានផ្តល់សក្ខីកម្មថា គាត់មិនដែលបានឃើញសៀវភៅនេះ នៅមន្ទីរសន្តិសុខ ស-២១ នោះទេ ដោយសារគាត់ផ្តោតទៅលើចម្លើយសារភាពតែប៉ុណ្ណោះ (ប្រតិចារឹក ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦ ទំព័រ ៦០-៦២)។ លើសពីនេះទៀត គ្រប់ភាគីទាំងអស់មានឱកាសសួរដេញដោលសាក្សីទាំងពីររូបនេះ ក៏ដូចជាខ្លឹមសារនៃបញ្ជីស្រដៀងគ្នានេះយ៉ាងច្រើន ដែលពួកគេអាចរកបាននៅពេលដែលសាក្សីមកផ្តល់សក្ខីកម្ម (*សូមមើល ឧទាហរណ៍* ឯកសារ E3/10075, E3/10036)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា វាពុំមានភាពចាំបាច់ក្នុងការកោះហៅសាក្សីទាំងនេះ នោះឡើយ។

៥. អង្គជំនុំជម្រះបន្តទទួលសំណើសុំឱ្យស្តាប់សក្ខីកម្មរបស់សាស្រ្តាចារ្យ Heynowski។